**ឆាកទី១**

*ផានីត និង តែកុង (គេឃើញផានីតនៅក្មេងពងស្គម កំពុងកត់ត្រា ចុះបញ្ជីសៀវភៅធំមួយ ទើបពូ ហំ ចំណាស់ពាក់កណ្តាលមនុស្សដើរចូលមកលបៗ។ ជនទាំងពីរឃើញគ្នាសម្លឹងគ្នាយូរបន្តិចទើបពូហំនិយាយ)*

*ពូហំ: លោកក្មួយមានរឿងអ្វី បានមើលពូតាំងពីក្បាលដល់ចុងជើង ហាក់ដូចជាយើងមិនដែលស្គាល់គ្នា?*

*ផានីត:ពូក្រែង...ក្រែងឡានពូ..*

***ហំ:**ថៅកែនៅហ្នឹងរឺទេ?*

*ផានីត:ចេញបាត់តាំងពីព្រលឹមម៉្ងៃះ*

***ហំ:** យី! ផ្ញើរម៉ានទៅគាត់ត្រឡប់វិញ ពូមានរឿងប្រញាប់ជាមួយនឹងគាត់ផង។*

***ផានីត:** មើលទៅបន្តិចទៀតគាត់ នឹងអញ្ជើញមកវិញហើយ។*

***ហំ:** ចុះពួកអាជេងអស់នះ កំពុងតែរៀបចំ ធ្វើឡានអាផាគោរី?*

***ផានីត:** បាទ!*

***ហំ:** ទៅមើលពួកអាជេងអស់នោះមួយភ្លែតសិន!(ដើររួចទុចវិញ)ណ្ហើយកុំឱ្យវាឃើញមុខនាំពិបាកចិត្តទេ។*

***ផានីត:** អញ្ជើញអង្គុយទៅពូ(ពូហំធ្វើតាម)ខ្ញុំឡើងទៅផ្ទះសិន(ផានីតក៏ដើរយ៉ាងលឿនចេញពីទីនោះ ហាក់ដូចជាខ្លាចមិនហ៊ានអង្គុយជាមួយតែកុង)។*

***ហំ:** លោកក្មួយកុំទៅណាអង្គុយនៅនេះហើយឱ្យបានពីរនាក់គ្រាន់បានជាគ្នា(ផានីតក៏ត្រឡប់មកអង្គុយវិញតែធ្វើជាបើកសៀវភៅធ្វើការ)។*

*តែកុងឡានជក់ខ្លះ ហួចខ្លះ ច្រៀងខ្លះ ទើបនិយាយថា:*

*យី! ចំតែម្តងហើយថៅកែទៅណាក៏ក្រមកម៉្ងៃះ។លោកក្មួយមានឮនរណាគេនិយាយថាអ្វីពីខ្ញុំទេ?*

***ផានីត:** ឮគេនិយាយតែរឿងហ្នុង!*

***ហំ:** រឿងស្អី រឿងហ្នុង!*

***ផានីត:** រឿងពីម្សិលទុំះណ៎ា! ថាលោកបើកឡានទៅបុកឡានអុងប៉ាងហុងលីស្លាប់មនុស្សអស់៣នាក់ និងមានរបួសជាច្រើន។*

***ហំ:** រួចដូចម្តេចទៀត?*

**ផានីត:** ថាលោកពូរត់បាត់ៗ ពូ..រាជការប្រកាសឱ្យគេរកចាប់ខ្លួន មានទាំងផ្សាយតាមវិទ្យុផង ថាបើនរណាឃើញរូបលោកពូឱ្យទៅជំរាបរាជការ។ ចុះពូឯងមកធ្វើអ្វីកន្លែងនេះតិចគិញមករកមើល ម្ដេចមិនគិតឱ្យបាត់ខ្លួនទៅ។

**ហំ:** (សើច)មុខតែនឹងគេចហើយ តែធ្វើម្ដេចឱ្យបានជួបថៅកែបើកលុយសិន។

**ផានីត:** ប្រាក់ខែបន្តិចបន្តួច ពូអើយកុំស្ដាយ។ ចាំទៅៗតិចមានគ្រោះថ្នាក់ធំ បើលោកពូត្រូវការលុយធ្វើសាហ៊ុយខ្វះ ខ្ញុំជូនខ្វះបាន(ផានីតហូតកាបូបចង់រាប់លុយឱ្យតែកុងខ្វះ)។

**ហំ:** (រាដៃមិនព្រមទទួលលុយ)ទុកចាយចុះលោកក្មួយ ពូមានហើយ។ លោកក្មួយឯងមុននឹងមកធ្វើការនៅទីនេះ នៅឯណាពីមុន?

**ផានីត:** នៅរៀនវិទ្យាល័យស៊ីសុវត្ថិ។ ខ្ញុំបានខំណាស់ដែរតែប្រលងចេះតែធ្លាក់លូវមិនចង់ត្រឡប់ទៅស្រុកសោះព្រោះខ្មាស់គេក៏មកសុំធ្វើការនៅនេះយកលុយរៀនឈ្នួលយប់ៗទៀត។

**ហំ:** ក្មួយឯងអាយុប៉ុន្មានហើយ?

**ផានីត:** ចូលឆ្នាំថ្មីនេះទៀត បាន១៧ហើយ។

**ហំ:** នៅក្មេងណាស់ គ្មានទាន់បានដឹងរឿងកន្ទុកកន្ទៀតជីវិតបន្តិចសោះ។ ពូមកនេះមកបើកលុយរង្វាន់មិនមែនមកបើកប្រាក់ខែទេប្រាក់ខែបើកចាយអស់១ខែមុនស្រេចទៅហើយ។

**ផានីត:** រង្វាន់ដោយពូបានធ្វើការយូរណាស់មកហើយឬ? ខ្ញុំបើធ្វើការយូរៗទៅថៅកែថានឹងឱ្យរង្វាន់ខ្ញុំដែរ គឺប្រាក់ចំណេញ ដែលត្រូវចែកគ្នា តាមភាគៗនោះឬ!

**ហំ:** រង្វាន់នោះ ពូគ្រាន់តែនិយាយ តែគេមិនដែលចែកទេ។ រង្វាន់ពូគឺរង្វាន់ក្ដៅៗ។ គឺថៅកែណ៎ា ដែលជាអ្នកបញ្ចេះឱ្យពូបុកឡាន អាហុងលីឱ្យវាមានគ្រោះថ្នាក់ គេលែងហ៊ានជិះតែឡានយើងហើយថៅកែសន្យាថា បើពូធ្វើបានគាត់ឱ្យរង្វាន់១ម៉ឺនរៀល។ រឿងនេះជារឿងសម្ងាត់កុំនិយាយឱ្យសោះ។

**ផានីត:** យី! អូអញ្ចឹងម្សិលមិញ គឺពូបុកឡានវាដោយចេតនាតែម្ដង។

**ហំ:** នឹងហើយ! ដាក់អាមួយម៉ោងមួយរយ ទាន់អាឯងព្រលែងចំកណ្ដាលថ្នឹងជំនីរ។

**ផានីត:** យី! ពូហ៊ានធ្វើអញ្ចឹង!

**ហំ:** មិនហ៊ានឯណា "មួយម៉ឺនរៀល"..។

***ផានីត:*** *ចុះមានអ្នកជិះបានស្លាប់ ដោយពូឯងបុកឡាននោះ។*

***ហាំ:*** *ពួកនោះវាស៊យ វាអាយុវាអស់។ អ្នកណាដឹងធ្វើម៉េច។*

***ផានីត:*** *ចុះសម្លាប់បើរាជការគេមករកចាប់ពូឯង?*

***ហាំ:*** *ឱ្យតែបានមួយម៉ឺនគេចប្រាវឥឡូវ។ យូរៗក្មេចខ្លួនបន្ទំផ្លាស់ឈ្មោះមកវិញដដែល។ ហើយម៉្យាងទៀតថៅកែ គាត់សន្យាថាគាត់ជួយគិតគូរគេឯង។ រឿងអ្វីតែមានលុយហើយ វាមិនដែលទៅជាធំរួចទេ។*

***ផានីត:*** *ខ្ញុំ បើថៅកែប្រើបែបនេះ ទុកជាឱ្យលុយយ៉ាងណាក៏មិនហ៊ានដែរ។*

***ហាំ:*** *ចុះបើក្មួយធ្វើការរាជការ និយាយឱ្យត្រង់ណា! តើលោកក្មួយហ៊ានស៊ីសំណូកឬទេ? និយាយឱ្យត្រង់ណា!*

***ផានីត:*** *ខ្ញុំមិនហ៊ានថាទេ។*

***ហាំ:*** *ឃើញទេរឿងស៊ីសំណូក និងរឿងបែបពូនេះ មិនខុសគ្នាប៉ុន្មានទេ។*

***ផានីត:*** *ពូឯងសម្លាប់គេទាំងរស់ណា។*

***ហាំ:*** *ចុះស៊ីសំនូកមិនកាច់កគេទាំងរស់! ចុះបំបាត់លុយរាជការ មិនកាច់កគេទាំងរស់! អ្នករកស៊ី បំបាត់គេគ្រប់យ៉ាង មិនកាច់កគេទាំងរស់!*

***ផានីត:*** *ឱពុទ្ធោអើយ!ខ្ញុំ យ៉ាងណាក៏មិនហ៊ានដែរ ទុកជាគេឱ្យប៉ុន្មាន ក៏មិនហ៊ានសម្លាប់មនុស្សដែរ។*

***ហាំ:*** *កុំអាលរកពុទ្ធោ! បើមិនសម្លាប់គេមានតែទុកឱ្យគ្នាឯងស្លាប់! ក្មួយរើសមើល៍ យកខាងណា?*

***ផានីត:*** *ខ្ញុំមិនយល់ទេពូ ពូឯងចង់ថាដូចម្ដេច អំបាញ់មិញ?*

***ហាំ:*** *ថា "បើមិនដាច់ចិត្តសម្លាប់គេតោងគ្នាឯងស្លាប់" តើគ្នាឯងស្លាប់ ក្មួយឯងធ្វើដូចម្ដេច?*

***ផានីត:*** *ម៉េចអញ្ចឹង?*

***ហាំ:*** *ពូត្រូវការលុយមួយម៉ឺនគ្មានមួយម៉ឺនប្រពន្ធពូងាប់ឈឺដើមទ្រូងក្អកខេះៗត្រូវការសម្រាកមិនធ្វើការ តើបានអ្វីស៊ី។ ទៅពេទ្យៗឱ្យសំបុត្រទិញថ្នាំចាក់។ពូគ្មានលុយទិញថ្នាំ ធ្វើម្ដេចទុកឱ្យប្រពន្ធស្លាប់ឬ? កូនស្រីពូប្រឡងជាប់ចូលអនុវិទ្យាល័យនារី សាលាតម្រូវឱ្យទិញសំពត់អាវ សៀវភៅ មុងតាមរបៀបគេ មិនទិញឱ្យកូនកូនខាតរៀន។ ខាតរៀនល្ងង់ដូចពូទៀត។ ធំឡើងវេទនា ម៉្លោះហើយត្រូវពូហ៊ានប្ដូរឱ្យកូនបានចំណេះនឹង*

គេ ទើបដោះបញ្ហានេះឱ្យបានស្រេចខំវិលវល់តែដដែលៗនៅតែល្វង់ព្រោះហេតុក្រនៅតែក្រ ព្រោះហេតុល្វង់ម៉្លោះហើយប្រថុយធ្វើម្ដេចឱ្យតែបានលុយនឹងបានចំណេះទៅ។ ម្ដាយពូគាត់ចាស់ហើយ ហើយគាត់ចង់ធ្វើបុណ្យមុននឹងគាត់អនិច្ចកម្មគាត់សុំលុយពូឱ្យពូធ្វើម្ដេច មិនឱ្យគាត់ធ្វើបុណ្យធ្វើទាន ហាក់ដូចជាធ្វើទណ្ឌកម្ម សម្ងាប់គាត់អញ្ចឹង... **ផានីត:** ពូយកលុយក្ដៅក្រហាយទៅជូនគាត់ យកទៅធ្វើបុណ្យ។ ក្រែងមិនបានបុណ្យណ៎ា?

**ហំ:** បាន ឬ មិនបានទុកមួយឡែកសិន ធ្វើម្ដេចឱ្យតែម៉ែបានស្រួលចិត្តដោយថាអញមានលុយធ្វើបុណ្យនឹងគេដែរ ស្រុកឥឡូវអញ្ចឹង គេកាប់ជ្រូកធ្វើបុណ្យ គេស៊ីសំណូកធ្វើបុណ្យ ឬគេធ្វើបុណ្យដើម្បីមានផ្លូវរកស៊ី គេសំពះព្រះសង្ឃ ដើម្បីឱ្យគេស្រលាញ់ (ផានីតគ្រវីក្បាលហួសចិត្ត)លោកក្មួយគ្រវីក្បាលហួសចិត្ត! នេះហើយជីវិតពិតៗដែលមិនមែនជីវិតតែពាក្យសម្ដីតែក្បួនខ្នាតបានថា សរុបសេចក្ដីឃើញថា ពូត្រូវតែប្រថុយឱ្យបានមួយម៉ឺនរៀលសិន។ ពូគិតស្រេចយូរណាស់មកហើយ ពូល្បងស្រាយរឿងនេះតាមវិធីច្រើនណាស់ហើយ តែទៅមិនរួចបានជាសល់តែផ្លូវមួយហ្នឹង ទើបប្រថុយទទួលថៅកែគាត់ត្រូវការស្រាប់ផង ចាំអីនឹងលេងមួយចានដើម្បីកសាងជីវិតវង្សត្រកូល។

**ផានីត:** ខ្ញុំឈប់ឮ ឈប់ឆ្លើយ ឈប់ដឹងហើយ!(ដើរចូលមកអង្គុយ)

**ហំ:** កើតមកជាមនុស្សហើយ ក្មួយមិនឱ្យឈប់ឮ ឈប់ឆ្លើយឈប់ដឹងបានទេ! ច្បាប់ជីវិតបង្ខំក្មួយឱ្យដោះស្រាយរឿងដែលមានចោទរាល់ៗថ្ងៃ។ បើក្មួយគេចមិនដោះស្រាយគឺក្មួយព្រមទទួលងាប់ជាមុនហើយស្រេច។

**ផានីត:** ខ្ញុំនឹកថា ខ្ញុំហើយជាមនុស្សអភ័ព្វជាងគេ កំព្រាឥតឪពុកម្ដាយ នៅជាមួយមាមីងគេអ្នកមានគេធ្វើបានគ្រប់យ៉ាងរកតែរៀនដោយចិត្តស្ងប់មិនបាន។ គេប្រើឆ្វេងស្ដាំផ្គាប់យ៉ាងដូចម្ដេចក៏មិនត្រូវខ្មោចចេញខ្មោចចូល និយាយតែពីមាន ពីសប្បាយផ្ទុយនឹងខ្ញុំដែលក្រ។

**ហំ:** មានមនុស្សវេទនាជាងក្មួយ ជាងមា ច្រើនណាស់ទៅទៀតលោកក្មួយ។ មានមនុស្សច្រើន បានព្រឹកខ្វះល្ងាចគ្មានអ្វីវ័ណ្ឌ គ្មានដំបូលជ្រក រស់ដោយសារលក់កម្លាំងប្រចាំថ្ងៃលោតែឈឺដេកចាំងាប់។ ជនទាំងនោះគេប្រៀបបានទៅនឹង សត្វដែលកើតគេទុកឱ្យរស់គ្រាន់តែសម្រាប់ធ្វើការផ្ដល់ផលឱ្យទៅជនមួយជំពូកទៀតដែលកើតមកចាំតែទទួលផល

ស្រាប់ដោយមិនចាំបាច់ធ្វើការឬដោយធ្វើការតែបន្ទិចៗ។ មួយថ្ងៃគិតតែប្រើស្មៀតបោករាប់មិនអស់។

**ផានីត:** នេះហើយសង្គមសក្តិភូមិ គ្មានរបៀបបណ្តោយមនុស្សប្រថុយគ្នាតាមចិត្តប្រកាប់ប្រចាក់គ្នាបោកបន្លំគ្នា លួចប្លន់គ្នា កេងប្រវ័ញ្ចគ្នា រហូតដល់ច្បាំងគ្នា ដើម្បីតែម្យ៉ាងគឺដើម្បីរស់ទៅតាមសេចក្តីលោភមិនចេះឆ្អែត។ នេះហើយសង្គមពុករលួយដែលអ្នកប្រសប់ចេះតែសប្បាយនៅចំពោះមុខមនុស្សភាគច្រើនដែលវេទនាពីរឿងរស់។ នេះហើយសង្គមនាយទុនមនុស្សជិះជាន់មនុស្សព្រោះពួកឈ្នះចេះរៀបចំគ្នាដើម្បីសង្កត់ពួកអ្នកចាញ់ឱ្យធ្វើការបង្កើតផលឱ្យខ្លួនរស់បានស្រួល។

**ហំ:** ក្មួយបានរៀន ក្មួយចេះរកពាក្យចំៗថាបាន។

**ផានីត:** ពូឯងហ្នឹងក៏សម្ងាប់គេដើម្បីខ្លួនរស់ដែរ។

**ហំ:** ពូមានចង់ឯណាក្មួយ តែជីវិតវាបង្ខំពូទេតើ! ដូចពូបានជម្រាបក្មួយរួចមកហើយស្រាប់។

**ផានីត:** ថៅកែ ហ្នឹងបង្ខំពូឯង។

**ហំ:** ថាដូចនេះក៏បាន។ តែចុះនរណាបង្ខំថៅកែ?

**ផានីត:** អ្នកណា! លោភចង់មានតែឯងហួសពេក។

**ហំ:** ត្រូវហើយថៅកែ គាត់ហ៊ានលោភ ព្រោះគ្មានច្បាប់ណាមកកម្រិតសេចក្តីលោភគាត់សោះ។ ដល់ចង់មានបានហួសកម្លាំងគាត់ សម្បត្តិគាត់កើនឡើងៗយូរៗទៅគាត់ទិញខ្មែរទាំងអស់មកប្រើ។

**ផានីត:** ពិតមែនហើយ ចុះផ្លូវដោះស្រាយ?

**ហំ:** កុំមាត់ឮសូរសំលេងអា "មែរសីដេស" ថៅកែមកហើយ។ នុ៎ះថៅកែមែន លោកក្មួយខ្ញុំលាលោកក្មួយឱ្យហើយណ៎ាព្រោះតែបានលុយមួយម៉ឺនចាយគ្នឹងហើយខ្ញុំ។

**ផានីត:** ចុះ ខ្ញុំពូឱ្យទៅណា?

**ហំ:** អង្គុយបូកលេខហើយ សង្វេគរឿងសង្គមតទៅទៀតចុះ។

**ផានីត:** ពូឯងពួនត្រង់នេះសិនទៅ ក្រែងថៅកែឃើញគាត់បើកឡានចេញគេចទៅណាទៀត។

**ហំ:** ក្មួយថានេះសមម្យ៉ាងដែរ(តែកុងក៏ពួនបន្តិចសិន)។

**ឆាកទី២**

*ផានីត ហំ ថៅកែ*

*ថៅកែ:(ដើរចូលមកមើលឃើញតែផានីតព្រោះពូហំពួនទៅហើយ) ផានីតមានមនុស្សចម្លែកមកសួរអ្វី..អីដែរ?*

***ផានីត:*** *បាទដូចជាមិនឃើញទេ។*

***ថៅកែ:*** *អញទៅស្នាក់ខ្ទប់ឯក្រសួងគិញហើយ តែមិនដឹងថាបានផលយ៉ាងណា? តែនៅផ្ទះប្រយ័ត្នមើលបើមានមនុស្សចម្លែកមកសួរ ឆ្លើយថាមិនដឹងៗទៅ។*

***ផានីត:*** *បាទ!*

***ហំ:*** *(ស្ទុះចេញពីកន្លែងពួនមក)ក្រាបប្រណិប័តន៍ថៅកែ*

***ថៅកែ:*** *យី! អាហំ អាឯងឆ្កួតទេឬ! មកធ្វើអ្វីហ្នឹង?*

***ហំ:*** *ប្របាទ...មក...សុំ....នៃ...នៃ*

***ថៅកែ:*** *អាឯងមិនដឹងជាគេប្រកាសតាមវិទ្យុរកចាប់ក្បាលទេ? រួចអាឯងមកនេះគិតសម្លាប់ទាំងអស់គ្នាហ:?*

***ហំ:*** *ខ្ញុំ ដឹងថាគេរកចាប់ខ្លួនខ្ញុំហើយ បានជាខ្ញុំឆ្លៀតមកបើកលុយរង្វាន់រួចនឹងអាលគេច។*

***ថៅកែ:*** *យី អានេះវង្វេងខួរហើយ គិតតែរង្វាន់ ជាប់គុកឯណោះមិនគិតទេ។ ទៅ!រត់ឱ្យបាត់ពីទីនេះទៅ!*

***ហំ:*** *ថៅកែ មេត្តាឱ្យលុយមកសិន!*

***ថៅកែ:*** *(ហូតកាបូបលុយ) ហ៏!យក២០០រៀល រួចទៅឯណាឱ្យបាត់ទៅអាចង្រៃវាយក៏*

***ហំ:*** *កាលដែលថៅកែ មានប្រសាសន៍នឹងខ្ញុំថាឱ្យខ្ញុំមួយម៉ឺន! ទាល់តែប៉ុណ្ណឹងដែរបានខ្ញុំប្រថុយលក់ស្បែក។*

***ថៅកែ:*** *យី អានេះ!អញមិនដឹង! បើ២០០មិនយកអញមិនដឹងអីទេ ទៅ!ចេញទៅ! ធ្វើឱ្យអញមានរឿងដោយសារផងឥឡូវមកលំអុករក១ម៉ឺនទៀតអាណាតាមអាឯងទាន់។*

***ហំ:*** *ព្រះតេជគុណ ខ្ញុំទុកជាម៉ែឪហើយ មេត្តាខ្ញុំចុះ។ ជីវិតខ្ញុំថ្លៃតែ១ម៉ឺនរៀលទេម្ដេចព្រះបាទម្ចាស់មានប្រសាសន៍ឯណាទៅវិញ។ ឱ្យខ្ញុំភ្ជាមមក១ម៉ឺនដូចជាបោះចោល ឱ្យសត្វលង់ទឹកទៅចុះ។ ព្រះតេជគុណស្គាល់ចិត្តខ្ញុំស្រាប់ហើយស៊ូស្លាប់រស់នឹងព្រះតេជគុណយ៉ាងណា។*

*ថៅកែ: យីអានេះ និយាយច្រើនណាស់ អញថាមិនដឹងៗហើយ។ យកឡានអញទៅបុកគេខូចឡានអញងាប់មនុស្ស៣នាក់ រឿងរ៉ាវនឹងអាឯងនេះសម្បើមណាស់ ប៉ោគេវាក្ដីផង ឥឡូវមករឹតឯងមួយទៀត។ ផានីតជួយគិតមើលអានេះវាគិតជញ្ជក់ឈាមឯង ឱ្យនៅតែស្បែកនឹងឆ្អឹងតែម្ដង។*

*ហំ: ព្រះតេជគុណជ្រាបស្រាប់ហើយ! ខ្ញុំបរឡានបុកគេ គឺធ្វើតម្រូវចិត្តព្រះតេជគុណ។*

*ថៅកែ: អញឱ្យបុកមែនតែអញមិនមែនឱ្យបុកទាល់តែស្លាប់មនុស្សឯណា?*

*ហំ: ខ្ញុំ ក៏មិនមែនចង់ឱ្យមានមនុស្សស្លាប់ដែរ។ តែនរណាប៉ាន់គ្រោះថ្នាក់បាន?*

*ថៅកែ: អើ! រួចអាឯងមកទារលុយអញទៀត?*

*ហំ: ចុះថៅកែសន្យាថា បើខ្ញុំបុកឡានាហុងលីបាន ឱ្យខ្ញុំ១ម៉ឺន។ ខ្ញុំទារតាមតែថៅកែសន្យា។(កម្មករចូល)។*

*ថៅកែ: អើ! អញឱ្យឯងបុកកុំឱ្យស្លាប់ ឥឡូវមានស្លាប់ រឿងវាធំអញមិនដឹងទេ។*

*ហំ: ថៅកែគ្មានបទបញ្ជាក់មុនថា កុំឱ្យមានស្លាប់ ឬ ឱ្យមានទេ។ ថៅកែគិតថាឱ្យតែបុកវាយកពីខាងសម្បើមថាពួកយើងសៀង ជាងពួកវាប៉ុននោះ ឥឡូវខ្ញុំធ្វើតាមបានហើយ រង្វាន់ដែលសន្មត់ថាឱ្យខ្ញុំឱ្យមកឥឡូវ១ម៉ឺនរៀល!*

*ថៅកែ: យី អាំ!សម្ដីរឹងណាស់ហ្ន៎!*

*ហំ: ថៅកែ ខ្ញុំបាទត្រូវការ១ម៉ឺនណាស់ ប្រពន្ធខ្ញុំឈឺកូនត្រូវចូលអនុវិទ្យាល័យ ម្ដាយខ្ញុំចង់ធ្វើបុណ្យបន្តិចបន្តួចនឹងគេ។ ឱ្យតែបាន១ម៉ឺនមកខ្ញុំយកទៅឱ្យប្រពន្ធកូនម្ដាយសប្បាយយ៉ាងណាយ៉ាងនោះចុះខ្ញុំឥតគិតទេ ខ្ញុំសូមលើកដៃសំពះថៅកែម្ដង បើមិនអាណិតខ្ញុំទេអាណិតតែប្រពន្ធកូនម្ដាយខ្ញុំចុះកុំតែមានវង្សត្រកូលខ្ញុំមិនត្រូវការ១ម៉ឺនធ្វើអ្វីទេ។*

*ថៅកែ: ឃើញទេអានេះ មានត្រង់នឹងឯងឯណា វាធ្វើការឱ្យឯងមិនមែនដោយស្រលាញ់ឯងទេ តែវាធ្វើឱ្យឯងដើម្បីសម្រាប់ប្រយោជន៍វាឯណោះឯងមិនទាំងអាណិតអញផង ចុះអញឱ្យអាណិតឯងម្ដេចបាន។*

*ហំ: ឥឡូវឈប់និយាយពីអាណិតខ្ញុំចុះ និយាយពីពាក្យដែលថៅកែដែលបានសន្យានឹងខ្ញុំ។*

*ថៅកែបានថា"អាហំអាឯងមើលស្រៀឡានអាហុងលី ឱ្យចំឆ្អឹងជំនីរអញឱ្យឯង១ម៉ឺនរៀល" ខ្ញុំបានបញ្ជាក់ថៅកែពីរបីដងថៅកែថាឱ្យ ១ម៉ឺនមែនឱ្យតែខ្ញុំធ្វើបាន។*

**ថៅកែ:** អញមិនដឹង អញមិនដែលនិយាយដូចនេះទេ អាឯងចង់ទៅប្ដឹងៗទៅអាឯង និយាយឱ្យបែកមេឃក៏គ្មានលោកណាជឿឯងដែរ។ នាម៉ឺនគេជឿអញអាសំអុយ។
**ហំ:** ថៅកែមិនខ្លាចខ្ពើទាល់ច្រកទេឬ? លេងបញ្ឆេះឱ្យប្ដឹងតិចខ្ញុំប្ដឹងមែនខ្ញុំមានសាក្សីខ្ញុំណាព្រោះកាលថៅកែនិយាយគឺថៅកែ និយាយនៅចំពោះមុខអាដែងអស់នោះ អាសុខ អាមាន  អាទ្រី អាគង់ សុទ្ធតែបានឮពួកទាំងនោះ វាទាំងបានឃាត់ខ្ញុំកុំឱ្យធ្វើផង។
**ថៅកែ:** (សើច)ពួកអាអស់នោះ វាមិនមែនឆ្កួតទៅសម្លាប់អញឱ្យអាឯងរស់នោះទេ។ ទុកជាឮមែន ឱ្យលុយវាខ្លះទៅ វាទៅជាមិនឮវិញហើយ។

ឆាកទី៤

ផានីត ថៅកែ និង តៃកុង
**ថៅកែ:** អញថាម៉ាត់ណា ម៉ាត់ហ្នឹងហើយ។ អាហំតិចលោថាអញមិនប្រាប់។ តែគេចាប់អញៗឆ្លើយថាអញមិនដឹងអ្វីទេ ហើយអញត្រូវចេញឈ្មោះប្ដឹងអាឯងទៀតផង ដោយចោទថាអាឯងធ្វើការខ្ជីខ្ជាបើកឡានអញទៅបុកឡាន អុងប៉ាង ហុងលី។
**ហំ:** ខ្ញុំសូមអរគុណថៅកែហើយៗដើម្បីតបគុណនេះ ខ្ញុំសូមជម្រាបថៅកែជាមុនវិញថាតែគេចាប់ខ្ញុំ ខ្ញុំឆ្លើយប្រាប់រាជការ នូវរឿងពិតហើយ គឺថៅកែបានប្រើខ្ញុំឱ្យធ្វើអំពើដ៏លាមកនោះមែនដោយសន្យាថាឱ្យខ្ញុំ១ម៉ឺនរៀល។
**ផានីត:** សូមទោស...ថៅកែ១ម៉ឺនរៀល ល្មមឱ្យទៅពូហំដែរ ដូចជាធ្វើទានឱ្យប្រពន្ធកូនម្ដាយ ឪពុកគាត់ចុះ។
**ថៅកែ:** (គំហក)ខ្ញុំនិយាយឯងដឹងរឿងអ្វីដែរ គិតតែកាន់បញ្ជីឱ្យត្រឹមត្រូវទៅមិនគិតទេ។ អញទៅជួបគេបន្តិចថៅកែធ្វើជាដើរចេញទៅ ពូហំចង់ដើរចេញទៅតាម ឃើញដូចនេះថៅកែក៏ចូលមកវិញពុទ្ធោ! ពុទ្ធោ! គ្មានឈ្នើងឯណាមកទាមខ្ញុំទេ ឱ្យជាប់ជាងឈ្នើងមនុស្សទេ។
**ហំ:** មិនដឹងនរណាជាឈ្នើង នរណាទេ ថៅកែជាឈ្នើង គូលីឬ គូលីជាឈ្នើងថៅកែ?
ឆាកទី៥
មនុស្សជជែកថែបនាងយ៉ាន(ប្រពន្ធពូហំ)ចូលមក
នាងយ៉ាន: (ដើរចូលមកដោយយំបណ្ដើរ ចូលមកឃើញថៅកែមុន មិនទាន់ឃើញប្ដី

*នាងទេ) ឱ! ព្រះតេជគុណម្ចាស់អើយ! ជួយខ្ញុំផងចុះ រឿងអ្វីបានជាបាត់ប្តីខ្ញុំមិនឃើញមក ផ្ទះហើយស្រាប់តែមានព្ទពួកគិញមកព័ទ្ធផ្ទះខ្ញុំ(យំ)។*

***ថៅកែ:*** *ឃើញទេអាហំ អញនិយាយអាឯងមិនជឿ (នាងយ៉ានក៏ឃើញប្តីខ្លួន)*

*យ៉ាន: យី! ពុកវា! តើមានរឿងអ្វី ប្រាប់ខ្ញុំឱ្យដឹងផង។*

***ហំ:*** *ខ្ញុំកំពុងតែ ដាត់បាយ ម៉ែគាត់ទើបនឹងមកពីវត្តមីកាទូចកំពុងរៀបចំសៀវភៅចាស់ៗ របស់វាស្រាប់តែមានមនុស្សពីរនាក់ចូលមកទ្វារមុខខ្ញុំក្រឡេកមើលទៅខាងក្រៅឃើញពីរ បីនាក់ទៀតពួនជុំវិញផ្ទះព្រលឹងខ្ញុំមិនដឹងទៅឯណាទេ ស្រាប់តែលោកមួយសួរខ្ញុំថា នែ អ្នកតៃកុងហំ ទៅឯណា? ខ្ញុំថា: លោកអើយបាត់តាំងពីព្រឹកម្សិល មិនទាន់ឃើញត្រឡប់ មកផ្ទះវិញផងខ្ញុំមិនដឹងដែរ។ លោកទាំងនោះក៏មើលសម្លឹងចោលភ្នែកពេញខ្ទមយើងរួច លោកម្នាក់ទតសួរទៅម៉ែថា"លោកយាយក្រែងបានដឹងថា តៃកុងហំនៅឯណាដែរឬ ម៉ែ លើកដៃសំពះហើយនិយាយថា: ចាស់ទេយកព្រះពុទ្ធធ្វើជាប្រធានខ្ញុំមិនបានដឹងទេ"។ ពួកអស់លោកក៏ថយទៅវិញទៅកាទូចលបមើលថាឃើញឡើងឡានហ្ស៊ីបទៅ។ ពួកជិត ខាងគេក៏មករោមយើងអ៊ូសួរថាពួកគិញមករកចាប់អ្នកហំហើយ។ ឱ!ពុទ្ធោអើយតើឪវា ឯងទៅធ្វើអ្វីនរណា?*

***ថៅកែ:*** *ខ្យ៉ានអើយ! អាហំវាឆ្កួតហើយ វាចង់ជាប់គុក វាចង់ផាប់អញអាណិតវាអញ ប្រាប់វាថាឱ្យវាគេចខ្លួនទៅវាមិនព្រម។ បន្តិចទៀតពួកគិញអូសក្បាលពីកន្ទែងនេះហើយ បើវានៅរឹងទទឹងអញដូចនេះ។*

*យ៉ាន: ចុះរឿងអ្វី! មានរឿងអ្វីបានជាគេរកចាប់?*

***ថៅកែ:*** *វាស្រវឹងឆ្កួត បើកឡានបុកឡានថៅកែហុងលី ពីម្សិលដោយមានគ្រោះថ្នាក់ស្លាប់ អ្នកជិះដល់ទៅ៣នាក់។*

*យ៉ាន: ឱពុទ្ធោអើយ!ដាច់ខ្យល់ស្លាប់ទៅល្អជាជាង។ ចុះឥឡូវត្រូវធ្វើដូចម្តេច?*

***ថៅកែ:*** *ធ្វើម្តេច! ថាឱ្យវាគេចសិន ឱ្យតែរួចមួយគ្រាសិនទៅ។ អញនឹងវែកផ្លូវទៅទៀត ហើយអញក៏មិនមែនធ្មេចភ្នែកមិនមើលខុសត្រូវលើខ្យ៉ានឯង យាយចាន់ និង កាទូចដែរ។*

*យ៉ាន: ចុះឪវា បើថៅកែគាត់មានប្រសាសន៍ដូចនេះហើយ នៅចាំធ្វើស្អីទៀតក៏ស្តាប់មិន បាន។*

***ថៅកែ:*** *អាហំ ឥឡូវប្លែកណាស់។*

*យ៉ាន: ឪវា!ខ្ញុំអង្វរថៅកែចុះ តែជាប់គុកហើយឈ្មោះយើងមិនល្អទេ។ គេឯងជិតខាង គេធ្លាប់ស្គាល់យើងគេថា"នំ! អ្នកហំជាប់គុកហើយ"។ កូនយើងដែលទៅរៀនគេថា នំ!កូននេះឪពុកវាជាប់គុកតើឱ្យគ្នាយកមុខទៅទុកឯណា? ម៉ែ បើគាត់ជ្រាបរឿងនេះហើយ គាត់នឹងព្រួយដាច់ខ្យល់មិនខាន។ ជាប់គុកលោតែគេបណ្ដើរឱ្យឯងមកធ្វើការជាប់ខ្នោះដៃស្មៀកខៀវពាក់ខៀវខ្ញុំខ្មាស់ដាច់ខ្យល់ហើយ។ ថៅកែគាត់និយាយយើង គោងស្ដាប់ គោងតាមគាត់ ដែលស្រឡាញ់យើងគាត់ចង់តែឱ្យយើងបានស្រួល ម្ដេចក៏ឪវាមិនព្រមធ្វើតាម កុំឈប់នៅស្ងៀមគិតមើលឱ្យមែនទែនអាណិតកេរ្ដិ៍ឈ្មោះកូនស្រី អាណិតម្ដាយអាណិតខ្ញុំ។ ស៊ូឱ្យបែកព្រាត់ប្រាស់កុំឱ្យមានឮថាមានគុក ពូជយើងក្រមែនតែគ្មាននរណាដែលជាប់គុកទេ។*

***ថៅកែ:*** *ហ៎ខ្យ៉ានយក៣០០រទៅ! ហង ១០០ យាយចាន់ ១០០ មីកាទូច១០០។*

***ហំ:*** *កុំយក! កុំធ្វើថោក រស់ដោយសារគេដាក់ទាននោះ!*

***ថៅកែ:*** *ខ្យ៉ានហង ជួយស្ដាប់មើលសម្ដីវា។ រស់តាំងពីនោះមកដោយសារអ្នកណាបើមិនដោយសារអញ? យក ៣០០ទៅខ្យ៉ាន អញធ្វើបុណ្យ។*

***ហំ:*** *កុំ! កុំព្រមទទួល បុណ្យពីមនុស្សបាប។*

*យ៉ាន: ឪវា ឯងថាអ្វីអញ្ចេះ ថៅកែគាត់ជាអ្នកមានគុណលើយើង។*

***ថៅកែ:*** *ហង ឮ នឹងត្រចៀកហងស្រាប់ហើយ តិចលោថាអញបញ្ចេះណា។*

*យ៉ាន: ចាស៎! ខ្ញុំក៏ឆ្ងល់ណាស់ដែរ។ ចុះគេខឹងថៅកែពីរឿងអ្វីរហូតដល់ដាក់ទានលុយកាក់មិនឱ្យយក? មានតែឯងខំរកលុយឱ្យ បានច្រើនហូរហៀរមក កុំបានព្រឹកខ្វះល្ងាច គ្មានអង្ករប្រចាំពាងគ្មានសំពត់អាវសម្រាប់ផ្លាស់? គ្មានអ្វីជាទៀងសម្រាប់ទ្រទ្រង់ជីវិតសោះ។*

***ហំ:*** *កុំយកមកនិយាយវែងពេកទៅផ្ទះ ទៅអីទៅ!*

*យ៉ាន: ឪវា! ខ្ញុំលែងយល់ឯងហើយ!*

***ហំ:*** *យល់ឬមិនយល់ ទៅផ្ទះទៅ រឿងអញស្រេចនឹងអញ ឯងកុំចេះដឹងអ្វី។*

*យ៉ាន: ខ្ញុំមិនទៅទេ។*

***ហំ:*** *នែ! និយាយឱ្យចេះស្ដាប់ ឯងមិនបានដឹងរឿងក្នុងកុំមកធ្វើជាចេះដែរ។*

*យ៉ាន: អាងអ្វីអាងតែគេមិនដឹងរឿង។ ឯងអ្នកចេះដឹង ម្ដេចក៏ធ្វើឱ្យថៅកែពិបាកដោយសារ?*

**ហំ:** មីនេះ គំនិតខ្ញុំគេក្រាស់ណាស់ ជ្រៅណាស់។

យ៉ាន: (យំកាន់តែខ្លាំង) បើខ្ញុំគេ ក៏វាមិនអីដែរ កុំឱ្យតែជាប់គុក។

**ហំ:** យី! មីនេះ!(ខឹងប្រលោត)

**ផានីត:** ពូហំ!ពូហំ! កុំប្រលោត បើមីងគាត់ល្ងង់ កុំយកសេចក្ដីល្ងង់ទៅតប។

**ថៅកែ:** អា ផានីត អាឯងចេះដឹងអ្វីដែរ? រឿងអាឯងគិតតែបូកលុយទៅតិចអញដេញចោលឱ្យឈប់ធ្វើការឥឡូវ។

**ផានីត:** បូកលេខមិនកើតទៀតទេ! វាប្រឡំខ្ចង់អស់ហើយ ឯងថាត្រូវស្រាប់តែខ្ចង់គេថាខុសទៅវិញ។ ក្បួនដែលគេបង្រៀនខ្ញុំឯសាលាទាំងប៉ុន្មានយកមកប្រើក្នុងជីវិតនេះមិនត្រូវសោះ។ ក្បួនប្រាប់ថាធ្វើនេះ"ល្អ"ជីវិតថា "ឆោត" ក្បួនថា "ចេះ" ជីវិតថា "ល្ងង់" ក្បួនថា "ទាប" ជីវិតថា "ខ្ពស់"។

**ថៅកែ:** អាផានីត ឈប់និយាយ អញដេញអាឯងឱ្យឈប់ធ្វើការឥឡូវហើយ។

**ផានីត:** មិនចាំថៅកែដេញទាន់ទេ ខ្ញុំឈប់មុនហើយ ព្រោះប្រមុះវាមិនចៀបខ្ញុំទ្រាំនៅជិតគំរង់មិនបានឡើយ។

**ថៅកែ:** អាផានីត...អាផានីត....

**ផានីត:** មានការអ្វីថៅកែ?

ឆាកទី៦

មនុស្សដដែលថែមកម្មករ សុខ ទ្រី មាន គង់

**ថៅកែ:** ចុះពួកអាអស់ទាំងនេះ ទៅណាមកណា ដើរចោលការ? យី! ពួកអានេះការនៅដៃវាហ៊ានដើរចោលការ។

គង់: ពួកខ្ញុំ ឮសូរមានការជជែកខ្លាំងពេក ហាក់ដូចជាមានរឿងធំបានជាបបួលគ្នាមកមើល។

**ថៅកែ:** ទៅ! នាំគ្នាទៅធ្វើវិញភ្លាមទៅ!

ទ្រី: បាទ! សួរសុខទុក្ខលោកបងហំបន្តិចសិន។

**ថៅកែ:** យី! អាឯងអស់នេះ វាឡើងចាង់ទាំងអស់គ្នាហើយ! អញនិយាយអ្វីក៏គ្មាននរណាស្ដាប់ដែរឥឡូវ។ បើដណ្ដើមតែធំទាំងអស់ បានអ្នកណាធ្វើគូលី អ្នកណាធ្វើថៅកែ? ឬមួយអាឯងអស់នេះដូចជាពួកគូលីឯទៀតៗ មួយថ្ងៃៗគ្មានធ្វើការអ្វីសោះជំនុំគ្នាតែពីគិត

បះបោរ តំឡើងប្រាក់ខែ។ អញប្រាប់ឯងមុនធ្វើជាមួយថៅកែណាទៀតបាន ជាមួយអញ មិនបានជាដាច់ខាត។ កើតមកជាមនុស្សក្នុងសង្គមវាតែងមានឋានៈខ្ពស់ទាបជាធម្មតា តាមចង្វាក់តាក់តែងមក។ ចុះបើយើងចេះតែបះបោរចង់ស្មើមុខដូចៗគ្នាតើបាននរណាធ្វើមេ នរណាធ្វើកូន? ស្តាប់បានទេ អាសុខ អាមាន?

សុខ: បាទ!

មាន: ព្រះបាទម្ចាស់!

***ថៅកែ:*** *អាគង់! អាទ្រី!*

អាគង់: មិនយល់ មិនដឹងជាថៅកែ ចង់ថាអ្វីអំបាញ់មិញ?

***ថៅកែ:*** *ល្ងើយ ទៅ អាមនុស្សមិនយល់ នៅតែមិនយល់ដដែលនេះឯង។*

(កម្មករទាំងអស់រៀបទៅ)។

***ផានីត:*** *កុំអាលអញ្ជើញទៅបងទាំងអស់គ្នា។ ខាតការមួយព្រឹកចុះថ្ងៃនេះចាំជួយស្តាប់ជួយព្រឿងពូហាំផង។*

***ថៅកែ:*** *អាផានីត អាណាធ្វើអ្វីឯង?*

***ផានីត:*** *ថៅកែ ឯងហ្នឹងធ្វើខ្ញុំ! ធ្វើឱ្យខ្ញុំធ្លួតចិត្តលើមនុស្សដែលឃើញតែពីលុយ ពីមាន។ រស់សព្វថ្ងៃរស់សម្រាប់តែគិតធ្វើម៉េចបើកលុយឱ្យហើយ។ ក្នុងការគិតនេះគ្មានគិតល្អជាទេ គិតតែពីរកល្បិចអយុត្តិធម៌លេងស្មៀត អាក្រក់គ្រប់យ៉ាង តាំងពីប្រើវិធីសូកប៉ាន់ វិធីកៀងមនុស្សឱ្យចូលដៃជាមួយខ្លួនរហូតដល់ធ្វើគ្រោងការសម្លាប់មនុស្សដែលអាចក្លាយទៅជាចំបាំងចក្រពត្តិ គ្រប់យ៉ាងដើម្បីឱ្យតែបានលុយ បានលុយច្រើនៗជាងគេ។*

***ថៅកែ:*** *(ស្រែក) អាផានីត! ចេញពីផ្ទះអញឱ្យឆាប់!*

***ផានីត:*** *ខ្ញុំចោទថៅកែ ឯងពេញទីថាជាចោរ ចោរជាន់ខ្ពស់។ ព្រោះចេះបន្លំតែពិតជាចោរអាក្រក់ជាងចោរឯទៀតៗផង។ ខ្ញុំ ចោទថៅកែឯងថា ជាមនុស្សសម្លាប់មនុស្ស ដូចជាសម្លាប់បីនាក់ក្នុងកាលបុកឡានពីម្សិល។*

***ថៅកែ:*** *មិនមែនអញទេ គឺអាហាំ។*

***ផានីត:*** *មិនមែនពូហាំទេ គឺថៅកែឯង ដួលពូហាំឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះដល់ពូហាំធ្វើហើយមិនព្រមឱ្យ១ម៉ឺនរៀលទៅគាត់ទៀត។ នេះហើយសេចក្តីពិត។ បងចូរដឹងបងមាន*

*បងសុខ បងគង់ បងទ្រី ជួយស្ដាប់ ជួយឮ ថៅកែយើងជាចិត្តចោរ ចោរប្លន់តែទាំងអស់គ្នា។*

***ថៅកែ:*** *ទេ!ទេ! អញមិនមែនចោរទេ។ ខ្យ៉ានជួយអញផង អាមាន អាគង់ អាសុខ អាទ្រី បើមានពួកគិញមកសួររឿងអ្វី តោងឯងជួយអញផង ចាំអញឱ្យលុយ។*

***ហំ:*** *នែ! មិត្តទាំងប្អូន! យើងជឿថា ឯងទាំងអស់គ្នាបានភ្ញាក់ខ្លះហើយ ថៅកែនេះគ្មានទឹកអាណិតយើង ស្រលាញ់យើងដូចសម្ដី តែងនិយាយនោះទេ គិតគិតតែពីប្រើយើងដើម្បីយកញើសឈាមយើង ទៅប្ដូរឱ្យបានលុយ ជួនកាលបោកយើង ដូចបានបោកអញជាកស្តុតាងស្រាប់។ លុះអំណាចចង់ចំណេញខ្លាំងពេកថៅកែមិនញញើតនឹងប្រើវិធីអមនុស្សឡើយ ពួកនេះគ្មានចេះស្នេហាជាតិ ដល់តិចតួចទេ មាតុភូមិរបស់គេគឺ "លុយ" នេះឯង។*

*យ៉ាន: ពុទ្ធោអើយ!*

*ថៅកែ: អាប្អូនអ្នកឯង គ្មានដឹងឮអ្វីទេណា! បើគេសួរចាំអញគិតឱ្យម្នាក់ៗ៥០០រ។*

***ហំ:*** *លុយ៥០០រ ចាយតែមួយភ្លែតអស់ហើយ។ ឬ សេចក្ដីយុត្តិធម៌ទៀតបើយើងយកមកដាក់ក្នុងខ្លួនបានហើយ មិនចេះសាបសូន្យទេ។ មិត្តទាំងប្អូន ត្រូវពិចារណាឱ្យមែនទែន។*

***ថៅកែ:*** *សេចក្ដីយុត្តិធម៌ មានតែឈ្មោះទេ! ក្នុងលោកនេះ គ្មាននរណាប្រតិបត្តិសេចក្ដីយុត្តិធម៌បានឡើយ។ ពីព្រោះ ឬ មួយតាមការពិតគ្មាន សេចក្ដីយុត្តិធម៌ទេ ឬ មួយជនមួយពួក ចេះតែមានរបៀបយល់លើសេចក្ដីយុត្តិធម៌ប្លែកៗគ្នា។ យុត្តិធម៌របស់ជនមួយក្រុមខុសនឹងយុត្តិធម៌របស់ជនមួយក្រុមទៀត។ ទាំងពីរក្រុមធ្វើអំពើផ្ទុយគ្នាស្រលះ តែក្រុមមួយៗសុទ្ធតែប្រកាសខ្លួនថាខ្លួនធ្វើតាមសេចក្ដីយុត្តិធម៌ទាំងអស់។ ដូចនេះនៅទីបំផុតមានតែ "លុយ" ទេ ដែលអាចធ្វើជាអាជ្ញាកណ្ដាល កាត់សេចក្ដីជជែក នៅលើសេចក្ដីយុត្តិធម៌ឬអយុត្តិធម៌។ យកលុយវិញទៅ អាប្អូននាក់ អញឱ្យម្នាក់ៗមួយពាន់រៀលបើឯងឆ្លើយថាមិនបានដឹងឮរឿងអ្វីទេ។*

***ផានីត:*** *បងទាំងប្អូន កុំឱ្យគេយកទឹកលុយមកទិញទឹកចិត្តយើងបាន។ កុំធ្វើជាមនុស្ស "សំបក" សុខចិត្តលក់គំនិតឱ្យគេអស់ នៅតែ "សំបក" ខ្លួនសម្រាប់ធ្វើការជាអាយ៉ងចាក់ត្មុកទៅតាមគេញាក់ដោយកម្លាំងលុយ។*

**ហំ:** មិត្តទាំងបួន ពេលនេះថៅកែត្រូវការឯង គេថាឱ្យឯងម្នាក់ៗ១ពាន់រៀលដល់គេផុត ត្រូវការឯងគេអាចប្រើស្មៀតមួយកាច់ពី ឯងម្នាក់ជាង១ពាន់រៀលទៀតវិញផង ពីព្រោះមនុស្សនេះគ្មានជឿលើសេចក្ដីយុត្តិធម៌លើអំពើល្អខ្ពស់ទាបឡើយ។

យ៉ាន: ឱ! ឪវាអើយ! ខ្ញុំទើបនឹងដឹងរឿង ថៅកែ យើងចិត្តចោរជាមនុស្សអាក្រក់ណាស់។

**ថៅកែ:** (និយាយតែម្នាក់ឯង) នៅទីបំផុត ខ្ញុំនៅតែម្នាក់ឯងទេដឹង? ទេដូចនេះមិនកើតទេ អញយកលុយអញចាយទាំងអស់ឱ្យតែអញបានបក្សពួក គ្រាន់ធ្វើជាគ្នាកុំឱ្យចិត្តអញកំព្រាពេក។ (ឮ)អាមាន! អញឱ្យឯង៣ពាន់ អាឯងថាដូចម្ដេច?

មាន: ថៅកែ...ថៅកែ...ចុះអាសុខ?

**ហំ:** គេប្រើស្មៀតបំបែកគ្នាយើងហើយ ត្រូវយើងចងគ្នាជាបាច់វិញឱ្យបានទើបផ្ដួលពួកជិះជាន់មនុស្សបាន។

សុខ: ណ្ហើយ លុយដែលថៅកែបម្រុងឱ្យពួកខ្ញុំ ថៅកែវេរទៅឱ្យលោកបងផងចុះ។

**ហំ:** ទេអាសុខ អញមិនព្រមយកលុយនេះទៀតទេ អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះដើម្បីសេចក្ដីពិតផ្ទុះឡើង រួចទើបបានដឹងឮគ្រប់ៗគ្នាហើយរកផ្លូវដោះស្រាយឱ្យបានឃើញ។

**ថៅកែ:** អញក៏មិនខ្វីឱ្យអាឯងដែរ លុយអញមាន អញសុខចិត្តដុតចោល។

**ផានីត:** លោកអើយជួយស្ដាប់ ពីរោះណាស់ មានលុយស៊ូដុតចោល ត្រង់អ្នកក្រមិនព្រមជួយ។

**ថៅកែ:** (ចង់រត់ចេញ)នៅជជែកជាមួយអាអស់នេះ មិនបានជាការសោះ!..

**ហំ:** ពួកយើងស្អាក់ កុំឱ្យចេញរួច ហ៊ុមថៅកែចិត្តចោរនាយទុនទុច្ចរិតនេះឱ្យជាប់ (ទាំងអស់គ្នាធ្វើតាមកម្មករទាំងបួន ធ្វើដោយញញើតញញើម)។

**ថៅកែ:** ណ្ហើយអាបួននាក់ អញនិយាយជាចុងបង្ហើយចុះ អាសុខ១ម៉ឺនអាទ្រី១ម៉ឺនអាគង់១ម៉ឺន។

មាន: ១ម៉ឺនថៅកែហ៊ានឱ្យ ១ម៉ឺន?

យ៉ាន: មានអើយ លុយបានដោយសំណូកក្ដៅក្រហាយ មានឯងយកទៅក៏ទុកបានមិនយូរដែរ។ លុយរកបានដោយងាយ ចាយក៏ដោយងាយប្រហែលជាមានឯង យកទៅលេង

ល្បែងចាញ់អស់ផងមើលទៅ ចុះដល់អស់លុយនោះទៅ មានឯងយ៉ាងដូចម្តេចទៅទៀត ក្រៅពីទឹកស្អាយថាអញបានករគេបានក្បត់មិត្ត អ្នកក្រដូចគ្នា។ រំពឹងលើថៅកែ គេមិនមែនជួយឯងមួយជីវិតទេគេមើលឃើញតែលុយនឹងគ្នា គេបីបួននាក់ប៉ុណ្ណោះ។

គង់: មែន!ពួកយើងកុំចាញ់បោកថៅកែ កុំចាញ់បោកអាពួកនាយទុនមូលធនដែលជាឈ្លើងជញ្ជក់ឈាមអារកយើងជិះជាន់យើង បឺតញើស បឺតឈាមយើងគ្រប់ពេលវេលា។ យើងត្រូវតែរួមគ្នាពួតដៃគ្នាចងសាមគ្គីឱ្យស្អិតរមួតហើយពុះពាររកសន្ទៅឱ្យទាល់តែឃើញ។

ទ្រី: អាគង់និយាយត្រូវ! ខ្ញុំមិនព្រមយកលុយ ១ម៉ឺនរបស់ថៅកែដើម្បីឱ្យមិត្តអ្នកក្រដូចគ្នាស្លាប់ដោយអយុត្តិធម៌ទេ។

**ផានីត:** បងគង់ បងទ្រី និយាយត្រូវណាស់។ ខ្លួនខ្ញុំ ក៏សុំចូលដៃជាមួយនឹងពួកបងៗដែរ។ យើងទាំងអស់គ្នាគោងរួមដៃគ្នាចង្អុលមុខចោរឱ្យចំចោរជាន់ខ្ពស់ដែលចេះប្រើវិធី និងគ្រឿងរាប់មិនអស់សម្រាប់បំផ្លាញសង្គមខ្មែរ សង្គមមនុស្ស។ ចោរបែបនេះ ខ្លាំងជាងចោរធម្មតាដែលលួចឬ ប្លន់ឯកជន ព្រោះចោរលួចប្លន់ហុតឈាមខ្មែរគ្រប់គ្នា ដោយប្រើវិធីបន្ទំបំបាត់សូកប៉ាន់និងអំពើអមនុស្សច្រើនទៀត។ ចោរនេះជាចោរប្លន់ជាតិ ប្រស់ចោរបែបនេះ មិនខ្លាចនឹងចូលដៃនឹងបរទេសលក់ជាតិខ្មែរដើម្បីខ្លួនបានចំណេញឡើយ។

ឆាកទី៧

ទាំងអស់គ្នាថែមពួកក្រុមនគរបាលចូលមក

សេហ្វ: អ្នកណាថា ឯណាចោរ? យើងជាក្រុមនគរបាល ប្រាប់មុខចោរយើងមកយើងចាប់។ (ទាំងអស់គ្នាជ្រួលភ័យ)

ភ្នាក់ងារទី២   កុំជ្រួលនៅឱ្យស្ងៀម!

**ថៅកែ:** អស់លោកមករកចាប់តែកុង ហំឬ? នុះ វា! ខ្ញុំជាថៅកែឡានឥឡូវខ្ញុំប្តឹងថែមទៀតព្រោះវាបានបំផ្លាញឡានខ្ញុំឱ្យខូចដែរ។

**ហំ:** បាទ!ខ្ញុំបាទនេះហើយ តែកុងហំ លោកចាប់ខ្ញុំចុះខ្ញុំមិនរត់ទេ ខ្ញុំព្រមទទួលថា បានប្រព្រឹត្តអំពើអមនុស្សធម៌មែនតែសូមលោកជ្រាបថា បើលោកចាប់ខ្ញុំ លោកត្រូវចាប់មនុស្សដែលបានណែនាំខ្ញុំឱ្យធ្វើអំពើឃោរឃៅនេះផង។ មនុស្សនោះខ្ញុំមិនបាច់ជម្រាប

*លោកទេទុកឱ្យពួកទាំងអស់គេជំរាបលោកជំនួសខ្ញុំចុះ ព្រោះខ្ញុំជាមនុស្សមានទោសក្រែង លោកថាសម្ដីខ្ញុំយកធ្វើការមិនកើត។*

***ថៅកែ:*** *(និយាយខ្សឹបៗ) អាប្អូននាក់អញឱ្យ ពីរម៉ឺន។*

*សេហ្វ: ទាំងអស់គ្នា តើមនុស្សណាមួយ?*

***ផានីត:*** *ថៅកែនេះឯង គាត់បានបញ្ចោះ ពូហំឱ្យបើកឡានបុកឡានអុងប៉ាងហុងលីដោយ សន្មត់ថាឱ្យពូហំ មួយម៉ឺនរៀល។*

***ថៅកែ:*** *អានេះ វាបង្កាច់ខ្ញុំទេលោក វាស្អប់ខ្ញុំ ព្រោះខ្ញុំមិនព្រមឱ្យឡើងប្រាក់ខែ។*

*យ៉ាន: លោកសេហ្វ! រឿងថៅកែបញ្ចោះនេះជារឿងពិតពួកកម្មករឡានទាំងអស់ប្អូននាក់ នេះជាសាក្សីស្រាប់ព្រោះបានដឹងដែរ។*

***ហំ:*** *អាមានជម្រាបលោកដោយត្រង់ទៅ។*

***ថៅកែ:*** *អាមាន...នែ..(ខ្សឹប)ពីរម៉ឺនរៀល។*

*សេហ្វ: ម្ដេចក៏នៅស្ងៀមទាំងអស់គ្នាហើយ! មើលឆ្លើយប្រាប់ខ្ញុំឱ្យត្រង់មកថា តើថៅកែ នេះបានប្រើតែកុងឱ្យបុកឡាន គេមែន ឬ ទេបើមែនថាមែន បើទេថាទេ (ចង្អុលទៅកម្មករ ទ្រី)មែនឬ អ្នក ឯណោះ?*

***ថៅកែ:*** *អាទ្រី*

***ហំ:*** *អាទ្រី*

*ទ្រី: មែន!*

***ថៅកែ:*** *វាភរទេ! វាភរទេ!*

*សេហ្វ: ចុះអ្នកនេះ?*

***ថៅកែ:*** *អាគង់អាណិតអញ!*

***ហំ:*** *អាគង់អាណិតខ្លួនអាឯង!*

*គង់: មែន!*

***ថៅកែ:*** *លោកសេហ្វ!កុំជឿវា វាចូលដៃគ្នា សម្លាប់ខ្ញុំហើយ។*

*សេហ្វ: ចុះអ្នកឯណោះទៀត?*

*មាន: មែន!*

*សុខ: មែន!*

***ថៅកែ:*** *ឱពុទ្ធោអើយ!*

*សែហ្វ: អ្នកនេះជាប្រពន្ធតៃកុងហំ ឬ?*

*យ៉ាន: ចាស៎ លោក! ប្ដីខ្ញុំបានបុកឡានថៅកែ ហុងលី ព្រោះចង់បានលុយ ១ម៉ឺនឱ្យខ្ញុំតាមសេចក្ដីសន្យារបស់ថៅកែដល់ប្ដីខ្ញុំបានធ្វើអំពើនោះ ហើយថៅកែនេះមិនព្រមទាំងបើកលុយ ១ម៉ឺនរៀលនោះឱ្យប្ដីខ្ញុំផង។*

*សែហ្វ: បាទ!បាទខ្ញុំ យល់ហើយរឿងនេះ(ចង្អុលទៅផានីត) ចុះលោកប្អូនឯណេះយល់ដូចម្ដេចដែរ។*

***ថៅកែ:*** *ក្មួយផានីតជួយមាផង។*

***ផានីត:*** *ខ្ញុំបានឱ្យយោបល់ហើយ តើឈ្មោះនេះឯង ដែលខ្ញុំស្រែក ចង្អុលថា ចោរនោះពេលដែលពួកលោកមកដល់។ (ថៅកែអួសដៃមេនគរបាលទៅខ្សឹប)។*

*សែហ្វ: តាងនាមក្រសួងនគរបាល ខ្ញុំសម្រេចថា ត្រូវនាំខ្លួនឈ្មោះហំ ទៅក្រសួងនគរបាលជាតិទៅចូលចាប់ (ភ្នាក់ងារនគរបាល ក៏ប្រតិបត្តិតាម។ (ចាប់តៃពូហំ)*

***ហំ:*** *អរគុណ ហើយមិត្តទាំងអស់គ្នា។ ម៉ែវាថែទាំកូននិងម្ដាយឱ្យបានស្រួលផង។*

***ថៅកែ:*** *ពួកអាឯងទាំងអស់គ្នា ឈប់ធ្វើការពីផ្ទះអញទៅ ទៅណាទៅចុះ!ពួកអាក្រតើ!*

*សែហ្វ: ទៅ! ទៅក្រសួងនគរបាល។ (ច្រាន និងវាយពូហំ)។*

*យ៉ាន: (ដោយស្រែកយំ) លោកអើយកុំធ្វើបាបប្ដីខ្ញុំ (រត់ចេញទៅ)។*

*គង់: ឱ!អ្នកក្រអើយ! តើខែណា! ឆ្នាំណា! សតវត្សណា!ទើបបំរះរួចពីការជិះជាន់បែបនេះ។ តើកាលណាទៅទើបមានយុត្តិធម៌។*

*សែហ្វ: ឈប់! ឈប់និយាយ(ប្រាប់នគរបាល) ចាប់វាភ្លាម! នគរបាលចូលចាប់ពូគង់ចង់ទៀត។*

***ផានីត:*** *បញ្ហាស្រដៀងៗគ្នាបានចោទពេញទំហឹង នៅក្នុងសង្គមខ្មែរសព្វថ្ងៃដែលទើបនឹងរួចពីការជិះជាន់របស់អាណានិគមការគ្រាន់តែចាប់ពូហំ ទៅដាក់គុក មិនមែនដោះស្រាយបញ្ហាទាំងនោះឱ្យបានស្រឡះទេនាទីយើងឥឡូវ គ្រាន់តែស្ដែងឡើងឱ្យលោកអ្នកចាប់អារម្មណ៍លើបញ្ហាសង្គមខ្មែរខ្វះ ឱ្យបានច្បាស់ផ្លូវត្រូវសម្រាប់ដោះស្រាយលោកទាំងអស់គ្នាជួយគិតចុះនៅពេលដែលលោក អ្នកបានមកឃើញរឿងប្រឌិត លើរឿងពិតនៃបញ្ហាខ្វះនៃសង្គមខ្មែរយើងរួចហើយនេះ។ ថ្ងៃទី ៩ ខែតុលា គ.ស ១៩៥៦*